ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិដំរៃ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ភូមិដំរៃ |
| ភូមិ | ៖ | ដំរៃ |
| ឃុំ | ៖ | បឹងចារ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិដំរ៉ែ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ភូមិដំរ៉ែ |
| ភូមិ | ៖ ដំរ៉ែ |
| ឃុំ | ៖ បឹងចារ |
| ស្រុក | ៖ សំបូរ |
| ខេត្ត | ៖ ក្រចេះ |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ..... ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..... ២
ក. ប្រជាពលរដ្ឋ ..... ២
ខ. មុខរបរ ..... ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ..... ៣
ក. ទីតាំង ..... ៣
ខ. ដែននេសាទ ..... ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ..... ៣
ឃ. ធនធានជលផល ..... ៤
៤. ការធ្វើនេសាទ ..... ៤
ក. អ្នកនេសាទ ..... ៤
ខ. ឧបករណ៍នេសាទ ..... ៤
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..... ៥
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៥
ក.ទស្សនៈវិស័យ ..... ៥
ខ. គោលបំណងរួម ..... ៦
គ. គោលបំណងជាក់លាក់ ..... ៦
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៦
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ..... ៦
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ..... ៨
ឃ.៣. ការគ្រប់គ្រង ..... ១១
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... ១៣
ច. យុទ្ធសាស្ត្រ ..... ១៤
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដំរីរយៈពេល៣ឆ្នាំ ..... ១៥
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩- មិថុនា ២០២២) ..... ២១

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិដំរ៉ែ ត្រូវបានបង្កើតឡើងតាមរយៈមហាសន្និបាតកំណើតដំបូងរបស់សហគមន៍ នៅឆ្នាំ ២០០៩ ក្រោមការគាំទ្របច្ចេកទេស និងថវិកាដោយខណ្ឌរដ្ឋបាលជលផលក្រចេះ និងអង្គការអុស្វាមអូស្ត្រាលី (CAA/Oxfam Australia) ដោយបានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង បញ្ជីឈ្មោះសមាជិក និងគណៈកម្មការ រចនាសម្ព័ន្ធគ្រប់គ្រង និងផែនទីកន្លែងនេសាទសហគមន៍។ បន្ទាប់មកសហគមន៍បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលក្រចេះ លើកដំបូងនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។ សហគមន៍នេសាទដំរ៉ែត្រូវបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។ ដោយអាណត្តិរបស់គណៈកម្មការមានរយៈពេលត្រឹមតែ ៥ឆ្នាំ និងយោងទៅតាមភាពចាំបាច់ សហគមន៍បានរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការឡើងវិញនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផល និងអង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន្ត(NRD) បន្ទាប់មកដោយសារក្នុងជួរសមាសភាពគណៈកម្មការមួយចំនួនលាឈប់ហើយមួយចំនួនទៀតបានផ្លាស់ប្ដូរទីលំនៅ ទើបនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ សហគមន៍នេសាទនេះត្រូវបានរៀបចំបោះឆ្នោតម្ដងទៀត ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផលក្រោមគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) ដោយគណៈកម្មការដែលទើបជាប់ឆ្នោតថ្មីមានចំនួន៩ នាក់ ក្នុងនោះស្ត្រីចំនួន២នាក់ ដោយបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត និងការឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់។ ក្រៅពីនោះដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផលក្រោមគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) ដដែល សហគមន៍ក៏បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទឡើងវិញតាមរយៈកិច្ចប្រជុំនៅថ្ងៃទី២០ ខែសីហា ឆ្នាំ ២០១៨ ដោយសមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការ សរុបចំនួន១៤៣ នាក់ ស្រីមានចំនួន៧៥ នាក់ ស្មើនឹង៦៦ គ្រួសារ និងបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តាមរយៈកិច្ចប្រជុំថ្ងៃទី១៥-១៦ ខែមករា ឆ្នាំ២០១៩ និងមហាសន្និបាតអនុម័ត ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅមានការជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង៖

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានបរិមាណត្រីថយចុះ មានការកាប់រានព្រៃលិចទឹកតាមមាត់ទន្លេ និងតាមដងព្រែកដើម្បីធ្វើកសិកម្ម

- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានខ្វះទីផ្សារលក់បន្លែដោយសារសហគមន៍កសិកម្មដែលបានបង្កើតឡើងហើយនោះនៅមិនទាន់មានដំណើរការល្អ និងតម្លៃលក់មាន់និងជ្រូកមិនស្ថិតស្ថេរ

- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានបទល្មើសនេសាទមានការកើនឡើងដូចជាឆក់ត្រី និងប្រើប្រាស់មងក្រឡាធំ (មងកាំងនៅរដូវប្រាំងនិងមងបណ្ដែតនៅរដូវត្រីពង) ដោយអ្នកនេសាទមកពីខាងក្រៅនិងអ្នកក្នុងភូមិ ប្រជាពលរដ្ឋខ្វះការយល់ដឹងលើផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងជលផល ការយល់ដឹងរបស់ប្រជាពលរដ្ឋលើស្មារតីអភិរក្សនៅ

មានកម្រិត អ្នកប្រព្រឹត្តបទល្មើសនេសាទមានបណ្ដាញ ហើយសហគមន៍នេសាទចុះល្បាតមិនបានទៀងទាត់ដោយសារខ្វះទូកសម្ភារៈនិងប្រេង ចំពោះការសហការគ្នារវាងសហគមន៍នេសាទជាមួយអាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធមិនទាន់បានល្អ សហគមន៍នេសាទមិនទាន់មានស្នាក់ការសម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ សហគមន៍នៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ និងលក់ដូរ ការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន៣៨៨នាក់ ស្រី១៩៥នាក់ ក្នុងនោះជនជាតិគួយ៧០% និងខ្មែរ៣០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%។

ប្រជាពលរដ្ឋក្នុងភូមិដំរីមានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន២០ នាក់
- ចំនួនជនពិការមាន៤ នាក់ ស្រី២ នាក់
- ចំនួនចាស់ជរាមាន៤ នាក់ ស្រី៤ នាក់
- ចំនួនកុមារកំព្រាមាន៥ នាក់ ស្រី២ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃមាន១០ នាក់ ស្រី១ នាក់
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន១៩នាក់ ស្រី១១នាក់ បឋមសិក្សាចំនួន៥៩នាក់ ស្រី៣៤នាក់ មធ្យមសិក្សាចំនួន២៤នាក់ ស្រី១២នាក់ និងឧត្តមសិក្សាចំនួន២នាក់ ស្រី២នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន៨៥ គ្រួសារ (៩១%)
- ធ្វើស្រែវស្សាចំនួន៩៣ គ្រួសារ ទំហំ៧៥ ហិកតា
- ដាំបន្លែចំនួន៣៤ គ្រួសារ
- ធ្វើចំការចំនួន១៦ គ្រួសារ
- ធ្វើជាងផ្ទះចំនួន២ គ្រួសារ
- សិប្បកម្មគ្រឿងសង្ហារឹម១ គ្រួសារ
- សិប្បកម្មមូក កញ្ជើ កញ្ច្រែង ល្អីចំនួន១ គ្រួសារ
- លក់ដូរចាប់ហួយចំនួន៧ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិដំរ៉ែជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិដំរ៉ែស្ថិតនៅតាមដងទន្លេមេគង្គ មានទំហំ១៨៩ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងភូមិកំពង់រទេះ និង ភូមិកោះដំបង ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងត្បូងទល់នឹងភូមិសំភិន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ
- ខាងកើតទល់នឹងភូមិកោះរាល ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងភូមិសំភិន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិដំរ៉ែ ស្ថិតនៅតាមដងទន្លេមេគង្គ មានព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ។ កន្លែងនេសាទសហគមន៍ភូមិដំរ៉ែ មានអន្លង់ចំនួន ៤ និង អូរចំនួន ៦គឺ៖

| | | |
|---|---|---|
| - អន្លង់សាលាឃុំ | ទំហំ ៨ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់ថ្មហា | ទំហំ ១,៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់ខ្សាច់ស | ទំហំ ១០ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់កន្ទុយកោះត្នោត | ទំហំ ០,១២ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អូរប្រហ៊ូត | ប្រវែង ៥០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - អូរគ្រែង | ប្រវែង ១.៥០០ ម៉ែត្រ | មានទឹកពេញមួយឆ្នាំ |
| - អូររាំង | ប្រវែង ១.២០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - អូរតាចេង | ប្រវែង ៥០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - អូរតាវ៉ាត | ប្រវែង ២.០០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - អូរតាជ័យ | ប្រវែង ២.៥០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា។ |

### គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សមាជិកសហគមន៍នេសាទបានឯកភាពគ្នាកំណត់យកអន្លង់សាលាឃុំ ទំហំ៨ ហិកតា (បណ្តោយ ១.០០០ ម៉ែត្រ និងទទឹង៨០ ម៉ែត្រ) និង អន្លង់កោះត្នោតទំហំ ០,១២ ហិកតា (បណ្តោយ៤០ ម៉ែត្រ និង ទទឹង៣០ ម៉ែត្រ) ជាតំបន់ដែលមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី ៖

ត្រីខ្យា ត្រីឆ្លាំង ត្រីតានេល ត្រីឆ្ដោក ត្រីក្រសក់ ត្រីក្អែក ត្រីក្ដី ត្រីក្រាយ ត្រីឆ្ដោ ត្រីរ៉ស់ ត្រីសណ្ដាយ ត្រីក្លាំងហាយ ត្រីប្រា ត្រីកែស ត្រីប្រាកណ្ដុរ ត្រីពោធិ៍ ត្រីព្រលូង ត្រីដំរី ត្រីប៉ាស៊ីអី ត្រីផ្ទក់ ត្រីឆ្ពួញ ត្រីខ្ទឹង ត្រីរៀល ត្រីក្រឡង់ ត្រីកញ្ចុះ ត្រីគ្រំ ត្រីក្រាញ់ ត្រីកន្ទ្រប់ ត្រីចេក ត្រីសារិកាកែវ ត្រីឆ្ពិន ត្រីកាហែ ត្រីច្រកែង ត្រីចង្វារ ត្រីអណ្ដែង ត្រីស្លឹកឫស្សី ត្រីកំភ្លាវ ត្រីតាអោន ត្រីគល់រាំង ត្រីបបែល ត្រីលលកស ត្រីស្លក់ ត្រីខ្មាន់ ត្រីក្រុស ត្រីកញ្ជ្រូក ត្រីអាចម៍កុក ត្រីកំបុតច្រមុះ ត្រីក្របី ត្រីកែ ត្រីឈ្កៀត ត្រីកំពត ត្រីផ្ទោង អន្ទង់ ត្រីខ្លា ត្រីប្រម៉ា ត្រីរាហ៊ូ ត្រីអណ្ដាតឆ្កែ ត្រីស្លាត ត្រីនាងល្វើង ត្រីកន្ទ្រង់ប្រេង ត្រីរមាស ត្រីតាយ៉ូ ត្រីខ្សាច់ ត្រីឆ្កុកដប ត្រីលេញ។

ឃ.២. ប្រភេទវារីសត្វ ៖

អណ្ដើក កន្ធាយ និង ល្មិច។

ឃ.៣. ព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមរ៉ៃ ដើមអញ្ចែង ដើមទន្លា ដើមត្រស់  ដើមរាំង ដើមក្ដុល ដើមផ្ដៅ ដើមត្រែង ដើមស្លូត ដើមបបុស ដើមឆ្នឹងពស់ ដើមបន្លាយួន ដើមឪឡឹង លាជផ្ទុះ ដើមប៉ាង និង ដើមក្របៅជាដើម។

**៤. ការធ្វើនេសាទ**

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៤៣ នាក់ ស្រី៧៥ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន១៤៥ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន៨០ នាក់ ស្រី៣០ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាងក្រៅភូមិ | |
| សំណាញ់ | វង់ | ២១ | | ១១ | ប្រវែង ៣,៥ម ក្រឡា១,៨-២ ស.ម | | ប្រវែង ៣,៥-៤,៥ ម ក្រឡា១,៨-២ស.ម | មករា - ធ្នូ |
| បង្កៃ | ផ្លែ | ៧៥០ | | | ផ្លែលេខ៥-១០ | | | មិថុនា - ធ្នូ |
| បង្កង | ផ្លែ | ២៥០ | | | ផ្លែលេខ១២-១៣ | | | មិថុនា - ធ្នូ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សន្ទូចរនង | សាង (១សាងស្មើរ ១០០ ផ្លែ) | ៤៥ | | ១៣៥ | ផ្លែលេខ១១-១២ | | ផ្លែលេខ៩-១២ | មករា - ធ្នូ |
| លប | គ្រឿង | ៥០ | | ២០០ | មុខ១ម បណ្តោយ២ម | | មុខ១ម បណ្តោយ២ ម | មិថុនា - ធ្នូ |
| ចាន់ | គ្រឿង | ២៤ | | ១២ | មុខ០,២៥ម បណ្តោយ១,២ ម | | មុខ(០,២៥-០, ម) កម្ពស់ ១,៣ ម | មិថុនា - ធ្នូ |
| មង | ត្បូង (១ ត្បូង៨០ ម) | ១៩៨ | | ៨០ | ក្រឡា ២-៦,៥ ស.ម | | ក្រឡា២-១៥ ស .ម | មករា - ធ្នូ |

ម = ម៉ែត្រ ស.ម = សង្ទីម៉ែត្រ

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន (ទូក) | | | ចំណុះ(គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកមានម៉ាស៊ីន | ៦៦ | ៦ | ៤០ | ៣០០-៥០០ | ៣០០-៥០០ | ៤០០ គ | ៦,៥-២០ | ៦,៥-២០ | ១៣-២០ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ(គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទ ភូមិដំរៃ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យធនធានត្រីនិងព្រៃលិចទឹកមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ អេកូទេសចរ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| ១. នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | មករា - ធ្នូ | សំណាញ់ | ប្រវែង ៣,៥ម ក្រឡា១,៨ -២សម | ៣០ វង់ | ១៥០ -(៥០/ឆ្នាំ សម្រាប់ការងារផ្សព្វផ្សាយ) |
| | មិថុនា - ធ្នូ | បង្កៃ | ផ្លែលេខ៥ - ១០ | ៧៥០ផ្លែ | |
| | មិថុនា - ធ្នូ | បង្គុង | ផ្លែលេខ១២ - ១៣ | ២៥០ផ្លែ | |
| | មករា - ធ្នូ | សន្ទូចរនង | ផ្លែលេខ៩ –១២ | ១៨០សាង (១សាង១០០ផ្លែ) | |
| | មិថុនា –ធ្នូ | លប | មុខ១ម បណ្តោយ២ម | ២៥០គ្រឿង | |
| | មិថុនា - ធ្នូ | ចាន់ | មុខ០,២៥ម បណ្តោយ១,៣ម | ៣៥គ្រឿង | |
| | មករា - ធ្នូ | មង | ក្រឡា២ - ៤សម | ២៧៨ត្បូង | |

ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់សាលាឃុំ | ៨ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | • ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់<br>• តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស<br>• លែងកូនត្រីពូជ | • ដាក់ពោង/ស្លាក (៤x ២០០=៨០០)<br>• តម្លើងផ្ទាំងផ្សព្វផ្សាយ (២x២០០=៤០០)<br>• លែងកូនត្រីពូជ (៣លើក x៥០០=១.៥០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់កន្ទុយកោះត្នោត | ០,១២ | | | | | |

ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| កន្ទុយកោះត្នោត | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍(ឱ្យស្ត្រីនិងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់) | ១ ផ្ទាំង | ១x៣០០=៣០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| តាមច្រាំងទន្លេ និងមាត់អូរ | ចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន ក្រែង រំ គ្រស់ រាំង | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៣០គ្រួសារ | ១.៥០០<br>៣០០ក្បាលx៥= | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមទាជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញ សម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៣០គ្រួសារ | ១.៥០០<br>៣០០ក្បាលx៥= | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញ សម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៤០គ្រួសារ | ១២.០០០<br>៤០ក្បាលx<br>៣០០= | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមក្របីជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៤០គ្រួសារ | ១២.០០០<br>៤០ក្បាលx<br>៣០០= | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ១០គ្រួសារ | ១.០០០<br>២០ក្បាលx៥០= | កក្កដា ២០១៩ | មិថុនា ២០២២ |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួន បន្លែជាគ្រួសារ | បន្លែ ៥មុខៈ (ស្ពៃ ត្រកួន ននោង សណ្តែកកួរ | ៦០គ្រួសារ | ៣.០០០<br>៦០គ្រួសារx៥០= | កក្កដា ២០១៩ | មិថុនា ២០២២ |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| | • ចែកគ្រាប់ពូជ<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | គ្រប់វែង គ្រសក់) | | | | |
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត និងធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ផ្សិតចំបើង និង ផ្សិតអំបោះ | ១០ គ្រួសារ | ៥០០<br>១០គ្រួសារx៥០= | កក្កដា ២០១៩ | មិថុនា ២០២២ |
| ធ្វើមេផ្សិត | • បណ្តុះបណ្តាលបច្ចេកទេសធ្វើមេផ្សិត | ផ្សិតចំបើង និង ផ្សិតអំបោះ | ១ គ្រួសារ | ៣០០<br>១គ្រួសារx៣០០= | កក្កដា ២០១៩ | មិថុនា ២០២២ |
| ដាំដំណាំហូបផ្លែ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំហូបផ្លែជាគ្រួសារ<br>• ចែកពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ប្រភេទដំណាំ ដូង គ្រអូប ក្រូចថ្លុងផ្អែម ក្រូចពោធិសាត់ | ៥០ គ្រួសារ | ១៥.០០០<br>៥០គ្រួសារx ៣០០= | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រី អណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ស្រះប្លាស្ទិក ឬ អាងស៊ីម៉ង់ចំនួន ០១/គ្រួសារ (ទំហំ ៤មx៦មx១ម) | ២០ គ្រួសារ | ១០.០០០<br>២០គ្រួសារx ៥០០= | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ចំនួន ១ ក្រុមបន្ថែម | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដាន និងត្រួតពិនិត្យ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ ១ ក្រុម | • ផ្សព្វផ្សាយទស្សនៈទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផលបន្ថែម<br>• ពិនិត្យ និងកែសម្រួលគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនបន្ថែមដល់ក្រុម<br>• តាមដាន និងត្រួតពិនិត្យ | ២០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សាងសង់ផ្លូវលំថ្មីបន្តទៅដល់កន្ទុយកោះឆ្នោតប្រវែង ២.០០០ ម៉ែត្រ ដែលត្រូវដាក់លូ២កន្លែង | ១ ខ្សែ | ២៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួសជុលផ្លូវលំក្នុងភូមិប្រវែង ៥.០០០ ម៉ែត្រ | ១ ខ្សែ | ៥០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួសជុលស្ពានឈើក្នុងភូមិ (ស្ពានអូរក្រែង) | ១ ស្ពាន | ១០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ដាក់លូឡើងវិញកាត់ទទឹងផ្លូវដែលមានស្រាប់ | ៥ កន្លែង | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួសជុលទំនប់ ប្រវែង១.៦០០ម៉ែត្រ | ១ កន្លែង | ១៦.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ស្តារប្រឡាយ ប្រវែង៣.០០០ម៉ែត្រ | ១ កន្លែង | ៦.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់បង្គន់អនាម័យតាមគ្រួសារបន្ថែម | ១៧ បង្គន់ | ៣.៤០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួលជុលបង្គន់អានាម័យតាមគ្រួសារដែលមានស្រាប់ | ១០ បង្គន់ | ៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២.៥. ផែនការពង្រឹងសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ

ផែនការពង្រឹងសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំវគ្គបណ្តុះបណ្តាលអំពីបដិសណ្ឋារកិច្ច | ៣ វគ្គ (១វគ្គ/ឆ្នាំ) | ៣០០ | មីនា ២០២០ | មីនា ២០២២ |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពទេសចរណ៍ធម្មជាតិ | ១ ផ្ទាំង | ៣០០ | មីនា ២០២០ | មីនា ២០២០ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង(៣ឆ្នាំ) | | ៦ដង/១ខែ | ៥.៤០០<br>៦ដងx១២ខែx៣x២៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ១០ អាវ | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | អាវភ្លៀង | ១០ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៤ គោម | | | |
| | វិទ្យុទាក់ទង | ៣ គ្រឿង | | | |
| | កែវយឹត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១០ | | | |
| | តង់គ្របទូក ៤មគុណ៦ម | ១ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រគុណភាពខ្ពស់(ស្លាបដែក) | ១គ្រឿង | | | |
| | សោរសម្រាប់ផ្ទួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ ឈុត | | | |
| | អាវកាក់ | ១០ អាវ | | | |
| ទិញទូកស្ទាច់ម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | ៧/២០១៩ | ៦/២០២២ |
| ប្រេងសម្រាប់ល្បាត (៣ឆ្នាំ) | | ១០០ លីត្រ/ខែ | ២.៨៨០<br>៨០លីត្រx៣៦ខែx១ | ៧/២០១៩ | ៦/២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ | ៦ដងx១០០=៦០០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍(ដីសាលាឆទាន) | | ១ កន្លែង | ៣.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |

ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦ដងx១០=៣៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦ដងx១០=៣៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកដាក់ឯកសារ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ | ៣លើកx២០=៦០ (៣ឆ្នាំ) | ៧/២០១៩ | ៦/២០២២ |

ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦ដងx២៥=១៥០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយដែននេសាទ និងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ៣ដងx១០=៣០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣ដងx១០០=៣០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៣ដងx២៥=៧៥ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣លើកx៥០=១៥០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣លើកx១០=៣០ (៣ឆ្នាំ) | | | គណៈកម្មាការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ១៧,៨៨ | ៥០០ រៀល/នាក់ (១៤៣នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ១២៣,៧៥ | ២.៥០០រៀល/គ្រួសារក្នុងមួយឆ្នាំ (៦៦ គ្រួសារ) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>•សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ១៩៣.២៤៨ | -ចំណាយ ១៩៣.៣៥០ ដុល្លារ<br>-ចំណូល ១៤១,៦៣ ដុល្លារ |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដងx១០= ១២០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | ៣ដងx២០០= ៦០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមាន សមាជិកគណៈកម្មការ និងសមាជិកសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិដំរី រយៈពេល៣ ឆ្នាំ (កក្កដា ២០១៩-មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១៥០ (៥០/១ឆ្នាំ) | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ពោង និងស្លាកសញ្ញាសំគាល់កន្លែងអភិរក្ស (ប្រើឬស្សីឬឬស្សី) | ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៤ ស្លាកត្រូវបានតំឡើង | ៨០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្សចំនួន ២ផ្ទាំងត្រូវបានតំលើង | ៤០០ | | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | លែងកូនត្រីពូជ | កូនត្រីពូជរួមមាន ត្រីប្រា ត្រីឆ្ពិន ត្រីឆ្ពោរ ត្រីខ្យា | ១.៥០០ (៥០០/១ឆ្នាំ) | | កក្កដា ២០១៩ | មិថុនា ២០២២ | |
